# I - ធីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ០៦ អនក្រ

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_ យោងស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីគោលការណ៍ប្រាក់កំរៃគរុកោសល្យ នៃបុគ្គលិកសិក្សា និង បញ្ហាពង្រឹងវិស័យគ្រប់គ្រងនៅរាល់គ្រឹស្ថានសិក្សា

_ ផ្អែកតាមសភាពការណ៍ចាំបាច់

### សំរេច

**មាត្រា ១ ..** ត្រូវបានបន្ថែមប្រាក់បៀវត្សចំនួន ២០.០០០ រៀល ( ពីរម៉ឺនរៀលគត់ ) ជាប្រាក់កំរៃគរុកោសល្យលើបៀវត្សបច្ចុប្បន្ន ជូនបុគ្គលិកសិក្សាគ្រប់ជាន់ថ្នាក់ ។

**មាត្រា ២ ..** ប្រាក់បន្ថែមដែលមានចែងក្នុងមាត្រា ១ ដែលត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៤ តទៅ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះរៀងខ្លួន។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ០៧ អនក្រ
## ស្តីពីការប្តូរឈ្មោះ វិទ្យាស្ថានបច្ចេកទេសកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ

**សំរេច**

**មាត្រា ១ -** វិទ្យាស្ថានបច្ចេកទេសកសិកម្ម ត្រូវបានប្តូរឈ្មោះជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម ( ស.ភ.ក ) សរសេរជាភាសាអង់គ្លេសថា ROYAL UNIVERSITY OF AGRICULTURE ( R.U.A )